# ផ្សែងពីភ្លើងឆេះរ៉ែធ្យូងថ្មពណ៌ត្នោត

## សន្លឹកព័ត៌មានសហគមន៍

Department of Health and Human Services បានរៀបចំព័ត៌មានទូទៅនេះ ដើម្បីឱ្យអ្នកបានដឹងពីអ្វីដែលត្រូវធ្វើដើម្បីការពារសុខភាពរបស់អ្នក និងសុខភាពរបស់នរណាម្នាក់នៅក្រោមការថែទាំរបស់អ្នក ដែលអាចប៉ះពាល់ចំផ្សែងក្នុងអំឡុងពេល ឬក្រោយពីភ្លើងឆេះរ៉ែធ្យូងថ្មពណ៌ត្នោត។

សម្រាប់ព័ត៌មានអំពីភ្លើងឆេះជាក់លាក់ ឬគ្រាអាសន្ន សូមស្តាប់វិទ្យុប្រកាសអាសន្នតាមស្ថានីយក្នុងតំបន់របស់អ្នកដើម្បីទទួលបានដំណឹងទាន់បច្ចុប្បន្នភាព ឬចូលទៅកាន់វិបសាយ www.emergency.vic.gov.au

ប្រសិនបើអ្នកស្ថិតនៅកន្លែងកើតហេតុអាសន្ន ត្រូវអនុវត្តជានិច្ចតាមការណែនាំអំពីសេវាសង្គ្រោះបន្ទាន់ ដូចជាមន្ត្រីទទួលបន្ទុកឡានពេទ្យ ប៉ូលីស ឬសេវាអគ្គីភ័យ។

### ចំណុចសំខាន់អំពីផេះពីភ្លើងឆេះរ៉ែធ្យូងថ្មពណ៌ត្នោតនៅក្នុងរដ្ឋវិចតូរីយ៉ា

- ផេះត្រូវបានផលិតនៅពេលធ្យូងថ្មពណ៌ត្នោតឆេះ។ ផេះនេះមានផ្ទុកនូវសមាសធាតុអុកស៊ីតនៃកាល់ស្យូម អាលុយមីញ៉ូម ប៉ូតាស្យូម សូដ្យូម ជាតិដែក និងម៉ាញ៉េស្យូម ហើយក្នុងករណីខ្លះមានផ្ទុកសមាសធាតុអុកស៊ីតនៃស្ពាន់ធ័រ។
- ភាគល្អិតៗនៃផេះធ្លាក់ចេញពីផ្សែងនៅក្នុងទីតាំងក្បែរជិតភ្លើងឆេះ។ ផេះគឺជាម្សៅម៉ត់ល្អិតៗ ដែលអាចមើលឃើញនៅលើផ្ទៃ។
- ទោះបីជាវាមានទំហំធំមិនអាចចូលទៅក្នុងសួតរបស់អ្នកតាមផ្លូវដង្ហើមក៏ដោយ ភាគល្អិតៗនៃផេះទាំងនេះអាចបង្កឱ្យលោកភ្នែក ច្រមុះ ឬបំពង់ក។ ផលប៉ះពាល់ទាំងនេះលើសុខភាពគួរជាបាត់យ៉ាងឆាប់រហ័ស។ ប្រសិនបើពុំជាបាត់ទេ សូមទូរស័ព្ទទៅ NURSE-ON-CALL លេខ 1300 60 60 24 ឬស្វែងរកឱវាទផ្នែកពេទ្យ។

### ចំណុចសំខាន់អំពីផ្សែងពីភ្លើងឆេះរ៉ែធ្យូងថ្មពណ៌ត្នោតនៅក្នុងរដ្ឋវិចតូរីយ៉ា

- ផ្សែងពីភ្លើងឆេះរ៉ែធ្យូងថ្មពណ៌ត្នោតមានផ្ទុកនូវភាគល្អិតតូចៗ ចំហាយទឹក ឧស្ម័នរួមទាំងកាបូនម៉ូណូអុកស៊ីត (carbon monoxide), កាបូនឌីអុកស៊ីត (carbon dioxide) និងអាសូតអុកស៊ីត (nitrogen oxides)។
- ផ្សែងពីភ្លើងឆេះរ៉ែធ្យូងថ្មពណ៌ត្នោតនៅក្រៅតំបន់ Latrobe Valley ក៏អាចមានផ្ទុកនូវសមាសធាតុអុកស៊ីតនៃស្ពាន់ធ័រផងដែរ។
- ចំពោះព័ត៌មានថ្មីៗទាន់បច្ចុប្បន្នភាពជាប្រចាំ អំពីកិច្ចការអ្វីខ្លះដែលអ្នកគួរធ្វើ សូមស្តាប់វិទ្យុប្រកាសអាសន្នក្នុងស្ថានីយតំបន់របស់អ្នក ឬចូលទៅកាន់វិបសាយ www.emergency.vic.gov.au
- អ្នកដែលមានជំងឺបេះដូង ឬជំងឺសួត រួមមានរោគហឺត កុមារ(អាយុរហូតដល់ទៅ១៤ឆ្នាំ) ស្ត្រីមានផ្ទៃពោះ និងមនុស្សចាស់អាយុលើសពី៦៥ឆ្នាំ គឺជាអ្នកងាយរងផលប៉ះពាល់នៃការដកដង្ហើមនៅក្នុងផ្សែង។
- ប្រសិនបើអ្នកមានជំងឺបេះដូង ឬជំងឺសួត ត្រូវលេបថ្នាំរបស់អ្នកតាមការណែនាំក្នុងសំបុត្រពេទ្យ។ អ្នកកើតរោគហឺត គួរតែអនុវត្តតាមផែនការសកម្មភាពការពាររោគហឺតរបស់ពួកគេ ហើយរក្សាថ្នាំបំបាត់រោគហឺតជាប់តាមខ្លួន។
- ប្រសិនបើអ្នក ឬនរណាម្នាក់នៅក្រោមការថែទាំរបស់អ្នកកំពុងមានអាការរោគដែលអាចកើតឡើងដោយសារត្រូវផ្សែង សូមទូរស័ព្ទទៅ NURSE-ON-CALL លេខ 1300 60 60 24 ឬស្វែងរកឱវាទផ្នែកពេទ្យ។
- នរណាម្នាក់ដែលជួបប្រទះនឹងបញ្ហាពិបាកដកដង្ហើម ដកដង្ហើមតឹងៗ ឬតឹងដើមទ្រូង គួរស្វែងរកជំនួយផ្នែកពេទ្យជាបន្ទាន់ - សូមទូរស័ព្ទលេខ 000។

### អំពីធ្យូងថ្មពណ៌ត្នោតនៅក្នុងរដ្ឋវិចតូរីយ៉ា

ធ្យូងថ្មកើតចេញពីការកកើតស្រទាប់នៃសារពើរុក្ខជាតិ អស់រយៈពេលជាងរាប់ពាន់ឆ្នាំមកហើយ។

ជាទូទៅ ធ្យូងថ្មពណ៌ត្នោតរដ្ឋវិចតូរីយ៉ាមានផ្ទុកនូវជាតិទឹកក្នុងបរិមាណច្រើន ស្ពាន់ធ័រក្នុងបរិមាណតិច និងសារធាតុកខ្វក់ក្នុងកម្រិតទាប។

នៅពេលកំពុងឆេះ ធ្យូងថ្មពណ៌ត្នោតរដ្ឋវិចតូរីយ៉ាផលិតផេះតិចតួច បើប្រៀបធៀបទៅនឹងប្រភេទធ្យូងថ្មផ្សេងទៀត។

ធ្យូងថ្មពណ៌ត្នោតតំបន់ Latrobe Valley មានផ្ទុកនូវបរិមាណស្ពាន់ធ័រតិចតួច (ទម្ងន់ស្ងួតតិចជាង 0.5%)។ ធ្យូងថ្មពណ៌ត្នោតតំបន់ Anglesea និង Bacchus Marsh មានផ្ទុកនូវស្ពាន់ធ័រ (ទម្ងន់ស្ងួត 4%)។

VICTORIA State Government | Health and Human Services

## តើមានសារធាតុអ្វីខ្លះក្នុងផ្សែងធ្យូងថ្មពណ៌ត្នោត?

ភ្លើងឆេះរ៉ែធ្យូងថ្មមានភាពខុសៗគ្នាក្នុងទំហំ រយៈពេលនៃការឆេះ និងបរិមាណផ្សែង ឬផេះដែលផលិតឡើង។

បរិមាណនៃផ្សែង ឬផេះធ្យូងថ្មនៅក្នុងសហគមន៍ ក៏អាស្រ័យលើស្ថានភាពអាកាសធាតុ និងចម្ងាយជិតយ៉ាងណានៃទីតាំងដែលមនុស្សរស់នៅ ឬធ្វើការងារក្បែរភ្លើងឆេះផងដែរ។

ផ្សែងពីភ្លើងឆេះរ៉ែធ្យូងថ្មពណ៌ត្នោត៖

- អាចកាត់បន្ថយគុណភាពខ្យល់ និងប៉ះពាល់ដល់សុខភាពរបស់មនុស្ស
- មានផ្ទុកនូវភាគល្អិតតូចៗ ចំហាយទឹក ឧស្ម័នរួមទាំងកាបូនម៉ូណូអុកស៊ីត កាបូនឌីអុកស៊ីត និងអាសូតអុកស៊ីត ហើយក្នុងករណីខ្លះ មានផ្ទុកនូវសមាសធាតុអុកស៊ីតនៃស្ពាន់ធ័រ
- មានផ្ទុកនូវភាគល្អិតនៃផេះ ដែលមានទំហំធំជាងភាគល្អិតតូចៗនៃផ្សែង។

## តើមានសារធាតុអ្វីខ្លះនៅក្នុងផេះផ្សែងធ្យូងថ្មពណ៌ត្នោត?

ផេះពីភ្លើងឆេះរ៉ែធ្យូងថ្មពណ៌ត្នោត៖

- ជាទូទៅ មាននៅជាមួយផ្សែង
- កកើតឡើងពីភាគល្អិតធំៗដែលមិនទាន់ឆេះអស់ ហើយធ្លាក់ចេញពីខ្យល់ទៅលើផ្ទៃជាម្សៅល្អិតៗ
- មានផ្ទុកនូវសមាសធាតុអុកស៊ីតភាគច្រើន នៃសារធាតុកាល់ស្យូម អាលុយមីញ៉ូម ប៉ូតាស្យូម សូដ្យូម ជាតិដែក និងម៉ាញ៉េស្យូម
- ស្រដៀងគ្នានឹងផេះ ដែលគេរកឃើញនៅក្នុងឡដុតកម្តៅផ្ទះ។

## តើផ្សែងអាចប៉ះពាល់ដល់សុខភាពរបស់ខ្ញុំដោយបែបណា ក្នុងអំឡុងពេលភ្លើងឆេះធ្យូងថ្មពណ៌ត្នោត?

ផ្សែងប៉ះពាល់ដល់សុខភាពរបស់អ្នក អាស្រ័យលើអាយុរបស់អ្នក ថាតើអ្នកមានជំងឺប្រចាំកាយឬអត់ អ្នកសកម្មកម្រិតណានៅក្នុងស្ថានភាពមានផ្សែងច្រើន និងរយៈពេលយូរប៉ុណ្ណាដែលអ្នកប៉ះត្រូវផ្សែង។

អ្នកដែលមានជំងឺបេះដូង ឬជំងឺសួត រួមមានរោគហឺត កុមារ(អាយុរហូតដល់ទៅ១៤ឆ្នាំ) ស្ត្រីមានផ្ទៃពោះ និងមនុស្សចាស់អាយុលើសពី៦៥ឆ្នាំ កាន់តែងាយរងផលប៉ះពាល់នៃការដកដង្ហើមនៅក្នុងផ្សែង។

ប្រសិនបើអ្នកមានជំងឺបេះដូង ឬជំងឺសួត ត្រូវលេបថ្នាំរបស់អ្នកតាមការណែនាំក្នុងសំបុត្រពេទ្យ។

អ្នកកើតរោគហឺត គួរតែអនុវត្តតាមផែនការសកម្មភាពការពាររោគហឺតរបស់ពួកគេ ហើយរក្សាថ្នាំបំបាត់រោគហឺតជាប់តាមខ្លួន។

ប្រសិនបើអ្នក ឬនរណាម្នាក់នៅក្រោមការថែទាំរបស់អ្នក កំពុងមានអាការរោគដែលអាចកើតឡើងដោយសារត្រូវផ្សែង សូមទូរស័ព្ទទៅ NURSE-ON-CALL លេខ 1300 60 60 24 ឬស្វែងរកឱវាទផ្នែកពេទ្យ។

សូមទូរស័ព្ទលេខ 000 ប្រសិនបើមាននរណាម្នាក់កំពុងមានបញ្ហាពិបាកដកដង្ហើម កំពុងជួបប្រទះបញ្ហាដកដង្ហើមតឹងៗ ឬតឹងដើមទ្រូង។

## តើផេះអាចប៉ះពាល់ដល់សុខភាពរបស់ខ្ញុំដោយបែបណា ក្នុងអំឡុងពេលភ្លើងឆេះធ្យូងថ្មពណ៌ត្នោត?

ភ្លើងឆេះរ៉ែធ្យូងថ្មបង្កើតឱ្យមានផ្សែង និងផេះ។

ទោះបីជាវាមានទំហំធំមិនអាចចូលទៅក្នុងសួតរបស់អ្នកតាមផ្លូវដង្ហើមក៏ដោយ ភាគល្អិតនៃផេះទាំងនេះអាចបង្កឱ្យរលាកភ្នែក ច្រមុះ ឬបំពង់ក។

ក្នុងករណីផលប៉ះពាល់ទាំងនេះមិនបានបាត់យ៉ាងឆាប់រហ័សនៅពេលអ្នកបានចេញឆ្ងាយពីផេះដែលកំពុងធ្លាក់  សូមស្វែងរកការប្រឹក្សាពីគ្រូពេទ្យ។

## តើខ្ញុំអាចធ្វើអ្វីខ្លះដើម្បីការពារសុខភាពរបស់ខ្ញុំ ក្នុងអំឡុងពេលភ្លើងឆេះធ្យូងថ្មពណ៌ត្នោត?

### ផេះ

ប្រសិនបើអ្នកបានប៉ះពាល់ជាមួយផេះ ត្រូវលាងវាចេញពីដៃ មុខ និងករបស់អ្នកជាការចាំបាច់។ ប្រសិនបើផេះចូលទៅក្នុងភ្នែករបស់អ្នក ត្រូវលាងចេញដោយថ្នមៗជាមួយទឹកស្អាត។

ត្រូវអនុវត្តអនាម័យឱ្យបានល្អ - ជូតសម្អាតផ្ទៃជាមួយសាប៊ូ និងទឹក។

### ផ្សែង

ក្នុងអំឡុងពេលមានភ្លើងឆេះ សូមស្តាប់វិទ្យុប្រកាសអាសន្នក្នុងស្ថានីយតំបន់របស់អ្នក ឬចូលទៅកាន់វ៉ិបសាយ www.emergency.vic.gov.au ដើម្បីទទួលបានដំណឹងទាន់បច្ចុប្បន្នភាពអំពីគុណភាពខ្យល់ និងកិច្ចការអ្វីខ្លះដែលអ្នកគួរធ្វើ។

ក្នុងអំឡុងពេលមានផ្សែងច្រើន ត្រូវជៀសវាងធ្វើលំហាត់ប្រាណ ឬសកម្មភាពប្រើកម្លាំងខ្លាំងនៅខាងក្រៅផ្ទះ។ អ្នកដែលមានជំងឺបេះដូង ឬជំងឺសួតប្រចាំកាយគួរតែសម្រាកឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន។

ប្រសិនបើអ្នកពុំមានការគំរាមកំហែងពីភ្លើងឆេះទេ ត្រូវស្នាក់នៅក្នុងផ្ទះឱ្យបានឆ្ងាយពីផ្សែង។ ត្រូវបិទទ្វារបង្អួចឱ្យជិត។

ប្រសិនបើអាកាសធាតុក្តៅ ហើយអ្នកបើកម៉ាស៊ីនត្រជាក់ ត្រូវប្តូរវាទៅមុខងារ 'recirculate' (បក់សារជាថ្មី) ឬ 'reuse air' (ប្រើខ្យល់សារជាថ្មី)។ ការនេះនឹងកំណត់ចំនួននៃកំទេចល្អិតៗក្នុងផ្សែង ចូលមកក្នុងផ្ទះ។

ប្រសិនបើផ្ទះរបស់អ្នកមិនផ្តល់ផាសុកភាព ហើយវាមានសុវត្ថិភាពក្នុងការធ្វើដូច្នេះ ត្រូវពិចារណាសម្រាកនៅឱ្យឆ្ងាយពីផ្សែង។ ត្រូវទៅទីកន្លែងដែលមិនរងផលប៉ះពាល់ដោយផ្សែង ឬចូលក្នុងអាគារដែលមានម៉ាស៊ីនត្រជាក់ក្នុងតំបន់ដូចជាបណ្ណាល័យ មជ្ឈមណ្ឌលសហគមន៍ ឬផ្សារទំនើប។

ប្រសិនបើមានសុវត្ថិភាពក្នុងការធ្វើដូច្នេះ ត្រូវឆែកមើលមនុស្សចាស់ដែលរស់នៅជិតខាង ឬមនុស្សឯទៀតដែលអ្នកគិតថាពួកគេអាចត្រូវការជំនួយបន្ថែម។

## ចុះប្រសិនបើពាក់របាំងមុខវិញ?

ជាការល្អដែលគួរស្នាក់នៅក្នុងផ្ទះឱ្យឆ្ងាយពីផ្សែង លុះត្រាតែអ្នកមិនអាចជៀសផុតពីការធ្វើការងារនៅខាងក្រៅអាគារ។

របាំងមុខការពារធូលីធ្វើពីក្រដាសធម្មតា កន្សែងដៃ ឬកន្សែងបង់ក អាចជួយកាត់បន្ថយការរងប៉ះពាល់ចំភាគល្អិតធំៗនៃផេះ ក៏ប៉ុន្តែមិនជួយការពារអ្នកពីកំទេចល្អិតៗក្នុងផ្សែង ឬឧស្ម័នទេ។

របាំងមុខពិសេស(របាំងមុខប្រភេទ P2) ផ្តល់នូវការការពារល្អប្រសើរពីការដកដង្ហើមនៅក្នុងកំទេចល្អិតៗក្នុងផ្សែង ។

មុនពេលសម្រេចចិត្តប្រើប្រាស់របាំងមុខប្រភេទ P2 ត្រូវចំណាំថា៖

- របាំងមុខអាចក្តៅ ហើយមិនស្រួលពាក់ និងធ្វើឱ្យកាន់តែពិបាកក្នុងការដកដង្ហើមដូចធម្មតា
- អ្នកមានជំងឺបេះដូង ឬជំងឺសួតប្រចាំកាយ គួរស្វែងរកការពិគ្រោះផ្នែកពេទ្យមុននឹងប្រើប្រាស់របាំងមុខ
- របាំងមុខមិនផ្តល់ការបិទជិតល្អទេ ប្រសិនបើអ្នកណាម្នាក់មានពុកចង្កា
- របាំងមុខមិនបានគេផលិតឡើងសម្រាប់ពាក់លើមុខកុមារទេ
- របាំងមុខមិនការពារអ្នកពីឧស្ម័ន ដូចជាកាបូនម៉ូណូអុកស៊ីតឡើយ។

## តើផេះអាចប៉ះពាល់ដល់សុខភាពរបស់ខ្ញុំឬទេ បន្ទាប់ពីភ្លើងឆេះធ្យូងថ្មពណ៌ត្នោត?

នៅពេលភ្លើងឆេះរលត់  គេអាចមើលឃើញផេះម្សៅល្អិតៗនៅលើផ្ទៃក្បែរជិតទីតាំងនៃភ្លើងឆេះ។

ផេះធ្យូងថ្មពណ៌ត្នោត ជាទូទៅមិនបង្កគ្រោះថ្នាក់ខ្លាំងទេ ក៏ប៉ុន្តែសំខាន់ត្រូវសម្អាតផេះដើម្បីការពារកុំឱ្យប៉ះពាល់ស្បែក ឬភ្នែក និងការកើតក្រហាយ។

## ការសម្អាតផេះ

ត្រូវអនុវត្តអនាម័យឱ្យបានល្អ - ជូតសម្អាតកម្រាលផ្ទៃក្នុងផ្ទះជាមួយសាប៊ូ និងទឹក។ ប្រសិនបើអាចមើលឃើញវានៅលើកម្រាលផ្ទៃ ត្រូវលាងជាមួយសាប៊ូ និងទឹក។

ត្រូវហាមឃាត់កូនក្មេងកុំឱ្យលេងក្បែរផេះ រហូតទាល់តែបានសម្អាតបរិវេណមានផេះនោះ។

ស្វែងរកការកឱវាទបន្ថែមទៀតពីសាលាក្រុងក្នុងតំបនរបស់អ្នក ទាក់ទិននឹងការសម្អាត។

## ខ្ញុំបារម្ភពីសុខភាពនៃសត្វចិញ្ចឹមរបស់ខ្ញុំ។ តើខ្ញុំគួរធ្វើអ្វីខ្លះ?

ក្នុងអំឡុងពេលមានផ្សែងច្រើន ហើយប្រសិនបើអាចធ្វើទៅបាន ត្រូវយកសត្វចិញ្ចឹមទៅក្នុងផ្ទះជាមួយអ្នក។

ប្រសិនបើលោកអ្នកមានកង្វល់ណាមួយ អំពីសុខភាពនៃសត្វចិញ្ចឹមរបស់អ្នក សូមពិគ្រោះជាមួយគ្រូពេទ្យសត្វក្នុងតំបន់របស់អ្នក។

## ខ្ញុំបារម្ភពីសុខភាពនៃសត្វរបស់ខ្ញុំ។ តើខ្ញុំគួរធ្វើអ្វីខ្លះ?

ប្រសិនបើអ្នកមានបញ្ហាកង្វល់ណាមួយ អំពីសុខភាពនៃសត្វរបស់អ្នកសូមពិគ្រោះជាមួយគ្រូពេទ្យសត្វ ឬមជ្ឈមណ្ឌលបម្រើអតិថិជនរបស់ Department of Environment, Land, Water and Planning Customer Service Centre តាមទូរស័ព្ទលេខ 136 186។

## តើខ្ញុំអាចផឹកទឹកពីអាងស្តុកទឹកភ្លៀងរបស់ខ្ញុំបានទេ?

ប្រសិនបើអ្នកមានអាងស្តុកទឹកភ្លៀងដែលភ្លក់ទៅមានរសជាតិ សភាព ឬក្លិនចម្លែក មិនត្រូវប្រើទឹកនេះសម្រាប់ផឹក ងូត ឬសម្រាប់សត្វចិញ្ចឹមឡើយ។

ចំពោះព័ត៌មានបន្ថែមសូមទាក់ទងមក ការិយាល័យសុខភាពបរិស្ថាននៅសាលាក្រុងក្នុងតំបន់របស់អ្នក ឬ Department of Health and Human Services។

## តើផេះពីភ្លើងឆេះរ៉ែធ្យូងថ្ម អាចប៉ះពាល់ដល់រុក្ខជាតិក្នុងសួនច្បាររបស់ខ្ញុំឬទេ?

ថ្វីបើផេះជាទូទៅពុំធ្វើឱ្យប៉ះពាល់ដល់សួនច្បារក៏ដោយ ផេះក្រាស់ច្រើនអាចគ្របដណ្តប់ ហើយធ្វើឱ្យរុក្ខជាតិងាប់ដោយថប់ដង្ហើម និងធ្វើឱ្យការរីកលូតលាស់ និងជីវិតរុក្ខជាតិមានកម្រិត។

## តើខ្ញុំអាចបរិភោគ ផ្លែឈើ ឬជីពីសួនច្បាររបស់ខ្ញុំបានឬទេ ប្រសិនបើវាមានផេះ?

ត្រូវប្រើចំណេះដឹងទូទៅជានិច្ច នៅពេលសម្រេចចិត្តថាតើអាហារមានសុវត្ថិភាពឬអត់ក្នុងការទទួលទាន។ គួរលាងទឹកសម្អាតបន្លែ ផ្លែឈើ ឬជីមុនពេលទទួលទាន ឬចម្អិន។

ប្រសិនបើអ្នកមិនចង់បរិភោគកសិផលរបស់អ្នកទេ អ្នកអាចបោះចោលបន្លែដែលរងប៉ះពាល់នោះ  ឬយកធ្វើជីកំប៉ុស។

## ផ្ទះរបស់ខ្ញុំមានក្លិនផ្សែង។ តើខ្ញុំគួរធ្វើអ្វីខ្លះ?

ប្រសិនបើផ្ទះរបស់អ្នកមានក្លិនផ្សែង បន្ទាប់ភ្លើងឆេះរលត់៖

- ត្រូវបើកបង្អួចទ្វារផ្ទះឱ្យចូលពន្លឺថ្ងៃ និងខ្យល់បរិសុទ្ធ
- ត្រូវហាលគ្រឿងសង្ហារិមទន់ៗ ក្រោមពន្លឺថ្ងៃ
- ត្រូវសម្អាតកម្រាលផ្ទៃក្នុងផ្ទះ ជាមួយសាប៊ូ និងទឹក។ ប្រសិនបើមានឃើញផេះលើកម្រាលផ្ទៃ ត្រូវលាងជាមួយសាប៊ូ និងទឹក។

## ចុះប្រសិនបើមានហាលសម្លៀកបំពាក់ចោលខាងក្រៅផ្ទះ?

ប្រសិនបើមានហាលសម្លៀកបំពាក់ចោលលើស្នូរ ក្នុងអំឡុងពេលមានផ្សែងច្រើន ត្រូវបោកលាងសម្អាតម្តងទៀតដើម្បីកម្ចាត់ក្លិនផ្សែង និងកំទេចផេះជាប់លើសម្លៀកបំពាក់ ដែលអាចធ្វើឱ្យលោកស្បែកដែលធាប់មានប្រតិកម្ម។ ប្រសិនបើនៅតែមានផ្សែង ត្រូវហាលសម្លៀកបំពាក់នៅក្នុងផ្ទះ ឬប្រើម៉ាស៊ីនសម្ងួត។

## ព័ត៌មានបន្ថែម

### Vic Emergency

សម្រាប់ព័ត៌មានបន្ថែមអំពីករណីពិសេស និងគ្រាអាសន្ន សូមចូលទៅកាន់វិបសាយ www.emergency.vic.gov.au

### ស្ថានីយ៍វិទ្យុប្រកាសអាសន្នក្នុងតំបន់

សម្រាប់ព័ត៌មានបច្ចុប្បន្នអំពីករណីពិសេស និងគ្រាអាសន្ន សូមស្តាប់វិទ្យុប្រកាសអាសន្នស្ថានីយក្នុងតំបន់របស់អ្នក។

### NURSE-ON-CALL

សម្រាប់ការប្រឹក្សាបន្ទាន់អំពីសុខភាព ពីគិលានុបដ្ឋាកដែលបានចុះបញ្ជីស្របច្បាប់ ២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ សូមទូរស័ព្ទលេខ 1300 60 60 24។

### Department of Health and Human Services

សម្រាប់ព័ត៌មានបន្ថែមពីផលប៉ះពាល់សុខភាព នៃផ្សែងមកពីភ្លើងឆេះនៅកន្លែងចាក់សំរាម ឬគុណភាពទឹកក្នុងអាងស្តុកទឹកភ្លៀង សូមទូរស័ព្ទលេខ 1300 761 874 ក្នុងអំឡុងពេលម៉ោងធ្វើការ។

### Environment Protection Authority Victoria

ព័ត៌មានអំពីគុណភាពខ្យល់អាកាស និងផលប៉ះពាល់ផ្សេងទៀតនៃភ្លើងឆេះទៅលើបរិស្ថាន និងការដឹកជញ្ជូន ហើយនិងការបោះចោលផេះពីភ្លើងឆេះធ្យូងថ្មពណ៌ត្នោត អាចទទួលយកបានពី EPA Victoria តាមទូរស័ព្ទលេខ 1300 372 842។

### សាលាក្រុងក្នុងតំបន់

សូមទាក់ទងសាលាក្រុងក្នុងតំបន់របស់លោកអ្នក ឬការប្រឹក្សាយោបល់អំពីគុណភាពទឹកក្នុងអាងស្តុកទឹកភ្លៀង។

ដើម្បីទួលយកឯកសារនេះក្នុងទម្រង់ដែលអាចចូលយកបាន សូមទូរស័ព្ទលេខ 1300 761 874 ដោយប្រើប្រាស់ National Relay Service លេខ 13 36 77 ប្រសិនបើតម្រូវ ឬអ៊ីម៉េល environmental.healthunit@dhhs.vic.gov.au

អនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលវិចតូរីយ៉ា 1 Treasury Place, Melbourne។

© រដ្ឋវិចតូរីយ៉ា Department of Health and Human Services ខែវិច្ឆិកា ឆ្នាំ២០១៦។